ក្រសួងឧស្សាហកម្ម
វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
លេខចូល 0606
ថ្ងៃទី: 14.2.24 ម៉ោង 4:00
បញ្ជូន: ថ្ងៃទី:

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ : ២៧ អនក្រ.បក**

# អនុក្រឹត្យ
# ស្តីពី
# ការទទួលស្គាល់ការប្រែក្លាយវិទ្យាស្ថានពាណិជ្ជសាស្ត្រ អេស៊ីលីដា ទៅជា សាកលវិទ្យាល័យពាណិជ្ជសាស្ត្រ អេស៊ីលីដា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០៥/០៩៧ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា១០ មាត្រា១១ មាត្រា១៤ មាត្រា១៥ និងមាត្រា១៦នៃព្រះរាជក្រឹត្យស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៧១ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា១០ថ្មី មាត្រា១៤ថ្មី មាត្រា១៥ថ្មី និងមាត្រា១៦ថ្មីនៃព្រះរាជក្រឹត្យលេខ នស/រកត/០២០៥/០៩៧ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៥ មាត្រា១៣ថ្មី មាត្រា៣០ថ្មី និងមាត្រា១១ថ្មីស្ទួននៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៩/២៤៣ ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០០៩ និងមាត្រា៦១ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា

- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ០១ អនក្រ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើតនិងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សានិងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ ស្តីពីក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា១ .-**

ត្រូវបានទទួលស្គាល់ការប្រែក្លាយវិទ្យាស្ថានពាណិជ្ជសាស្ត្រ អេស៊ីលីដា ទៅជា**សាកលវិទ្យាល័យពាណិជ្ជសាស្ត្រអេស៊ីលីដា** ដែលសរសេរជាអក្សរកាត់ថា **ស.ព.អ.** និងជាភាសាអង់គ្លេសថា ACLEDA University of Business សរសេរជាអក្សរកាត់ថា AUB។

**មាត្រា២ .-**

**ស.ព.អ.** ជាគ្រឹះស្ថានឧត្តមសិក្សាឯកជន មានអាសយដ្ឋានអគារលេខ១៣៩៧ មហាវិថីមិត្តភាពភ្នំពេញ-ហាណូយ ភូមិអន្លង់ក្ងាន សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ និងស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៣ .-**

**ស.ព.អ.** ធ្វើការបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្ររង បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ ដែលមានមហាវិទ្យាល័យចំនួន៥ និងសាលាក្រោយបរិញ្ញាបត្រចំនួន១ ដែលមានរចនាសម្ព័ន្ធដូចខាងក្រោម៖

**១- មហាវិទ្យាល័យហិរញ្ញវត្ថុនិងគណនេយ្យ**

ក- ដេប៉ាតឺម៉ង់ហិរញ្ញវត្ថុនិងធនាគារ
- កម្រិតបរិញ្ញាបត្ររង : ជំនាញហិរញ្ញវត្ថុនិងធនាគារ
- កម្រិតបរិញ្ញាបត្រ : ជំនាញហិរញ្ញវត្ថុនិងធនាគារ។

ខ- ដេប៉ាតឺម៉ង់គណនេយ្យនិងសវនកម្ម
- កម្រិតបរិញ្ញាបត្ររង : ជំនាញគណនេយ្យ
- កម្រិតបរិញ្ញាបត្រ : ជំនាញគណនេយ្យ។

គ- ដេប៉ាតឺម៉ង់គ្រប់គ្រងហានិភ័យនិងធានារ៉ាប់រង
- កម្រិតបរិញ្ញាបត្ររង : ជំនាញធានារ៉ាប់រង
- កម្រិតបរិញ្ញាបត្រ : ជំនាញគ្រប់គ្រងហានិភ័យនិងធានារ៉ាប់រង។

**២- មហាវិទ្យាល័យនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

ក- ដេប៉ាតឺម៉ង់វិទ្យាសាស្ត្រសេដ្ឋកិច្ច
- កម្រិតបរិញ្ញាបត្រ : ជំនាញសេដ្ឋកិច្ចពាណិជ្ជកម្ម។

ខ- ដេប៉ាតឺម៉ង់នីតិសាស្ត្រ

- កម្រិតបរិញ្ញាបត្រ : ជំនាញនីតិសាស្ត្រ។

គ- ដេប៉ាតឺម៉ង់គ្រប់គ្រងបណ្តាញផ្គត់ផ្គង់និងចលនូបត្ថម្ភ

- កម្រិតបរិញ្ញាបត្ររង : ជំនាញចលនូបត្ថម្ភ
- កម្រិតបរិញ្ញាបត្រ : ជំនាញគ្រប់គ្រងបណ្តាញផ្គត់ផ្គង់និងចលនូបត្ថម្ភ។

## ៣- មហាវិទ្យាល័យពាណិជ្ជសាស្ត្រ

ក- ដេប៉ាតឺម៉ង់គ្រប់គ្រងពាណិជ្ជកម្ម

- កម្រិតបរិញ្ញាបត្ររង : ជំនាញគ្រប់គ្រងអាហារ័ណ-នីហរ័ណ
- កម្រិតបរិញ្ញាបត្រ : ជំនាញពាណិជ្ជកម្មអន្តរជាតិ។

ខ- ដេប៉ាតឺម៉ង់ទីផ្សារ

- កម្រិតបរិញ្ញាបត្ររង : ជំនាញទីផ្សារ
- កម្រិតបរិញ្ញាបត្រ : ជំនាញទីផ្សារ។

គ- ដេប៉ាតឺម៉ង់គ្រប់គ្រង

- កម្រិតបរិញ្ញាបត្រ : ជំនាញគ្រប់គ្រងធុរកិច្ចនិងសហគ្រាស។

## ៤- មហាវិទ្យាល័យបច្ចេកវិទ្យានិងវិទ្យាសាស្ត្រ

ក- ដេប៉ាតឺម៉ង់បច្ចេកវិទ្យាព័ត៌មាន

- កម្រិតបរិញ្ញាបត្រ : ជំនាញបច្ចេកវិទ្យាព័ត៌មានធុរកិច្ច។

ខ- ដេប៉ាតឺម៉ង់វិទ្យាសាស្ត្រនិងវិស្វកម្មកុំព្យូទ័រ

- កម្រិតបរិញ្ញាបត្រ : ជំនាញវិទ្យាសាស្ត្រនិងវិស្វកម្មកុំព្យូទ័រ។

គ- ដេប៉ាតឺម៉ង់បច្ចេកវិទ្យាហិរញ្ញវត្ថុ

- កម្រិតបរិញ្ញាបត្រ : ជំនាញបច្ចេកវិទ្យាហិរញ្ញវត្ថុ។

## ៥- មហាវិទ្យាល័យសិល្បៈ មនុស្សសាស្ត្រ និងភាសា

ក- ដេប៉ាតឺម៉ង់ភាសាបរទេស

- កម្រិតបរិញ្ញាបត្ររង : ជំនាញភាសាអង់គ្លេស
- កម្រិតបរិញ្ញាបត្រ : ជំនាញភាសាអង់គ្លេសសម្រាប់ទំនាក់ទំនងធុរកិច្ច។

ខ- ដេប៉ាតឺម៉ង់អប់រំ

- កម្រិតបរិញ្ញាបត្រ : ជំនាញការបង្រៀនភាសាអង់គ្លេស។

គ- ដេប៉ាតឺម៉ង់បកប្រែ

- កម្រិតបរិញ្ញាបត្រ : ជំនាញភាសាអង់គ្លេសសម្រាប់បំណិនបកប្រែ។

## ៦- សាលាក្រោយបរិញ្ញាបត្រ

- កម្រិតបរិញ្ញាបត្រជាន់ខ្ពស់ :
  + ជំនាញហិរញ្ញវត្ថុនិងធនាគារ
  + ជំនាញហិរញ្ញវត្ថុ
  + ជំនាញគ្រប់គ្រង។

ក្នុងករណីចាំបាច់ដែល **ស.ព.អ.** ផ្លាស់ប្តូរទីតាំង ប្តូរឈ្មោះ បង្កើតសាខាថ្មី មហាវិទ្យាល័យថ្មី ដេប៉ាតឺម៉ង់ថ្មី ជំនាញថ្មី កម្រិតបណ្តុះបណ្តាលថ្មី ឬរៀបចំរចនាសម្ព័ន្ធមហាវិទ្យាល័យ ត្រូវស្នើសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៤ .-**

**ស.ពា.អ.** មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីត្រួតពិនិត្យនិងសម្រេចលើគោលនយោបាយ ផែនការអភិវឌ្ឍកម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធផ្សេងៗទៀត។ តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងជាក់ស្តែងនៃ **ស.ពា.អ.** ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល និងមានការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៥ .-**

សាកលវិទ្យាធិការនៃ **ស.ពា.អ.** មានភារកិច្ចដូចខាងក្រោម៖

- ទទួលខុសត្រូវចំពោះមុខច្បាប់ក្នុងការគ្រប់គ្រង **ស.ពា.អ.** និងធានាឱ្យមានសុវត្ថិភាពនិងសណ្តាប់ធ្នាប់សង្គម
- ទទួលខុសត្រូវក្នុងការជ្រើសរើសនិស្សិត ការទទួលនិស្សិតឱ្យចូលរៀន និងការបញ្ចប់ការសិក្សា ស្របតាមកម្មវិធីសិក្សារបស់ **ស.ពា.អ.** និងបទដ្ឋាននិងគោលការណ៍របស់ក្រសួងអប់រំ យុវជន និងកីឡា
- រៀបចំកម្មវិធីសិក្សាលម្អិតឱ្យស្របតាមលក្ខខណ្ឌនិងបទប្បញ្ញត្តិនៃក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- គោរពនិងអនុវត្តតាមបទដ្ឋាននិងគោលការណ៍ណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលកំណត់លើសកម្មភាពនៃការធានាគុណភាពអប់រំឧត្តមសិក្សា
- រៀបចំរបាយការណ៍ប្រចាំឆ្នាំអំពីការងារបណ្តុះបណ្តាលជូនក្រសួងអប់រំ យុវជន និងកីឡា នៅក្រោយដំណាច់ឆមាសទី២។

**មាត្រា៦ .-**

និស្សិតដែលបានបញ្ចប់ការសិក្សាដោយជោគជ័យ ត្រូវទទួលសញ្ញាបត្រតាមកម្រិតនិងជំនាញដែលបានសិក្សា។ សញ្ញាបត្រនេះ ត្រូវផ្តល់ឱ្យដោយ **ស.ពា.អ.** ផ្អែកលើបញ្ជីឈ្មោះនិស្សិតបញ្ចប់ការសិក្សាជាប់ជាស្ថាពរដែលមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៧ .-**

អនុក្រឹត្យលេខ១៣ អនក្រ.បក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦ ស្តីពីការទទួលស្គាល់វិទ្យាស្ថានពាណិជ្ជសាស្ត្រអេស៊ីលីដា និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៨ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាកលវិទ្យាធិការនៃសាកលវិទ្យាល័យពាណិជ្ជសាស្ត្រ អេស៊ីលីដា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៣កើត ខែ មាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានីភ្នំពេញ
- ដូចមាត្រា៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ